# ការយល់ឃើញរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាននៅកម្ពុជា៖ ការវិវឌ្ឍន៍ក្នុងរយៈពេល៧ឆ្នាំ (២០១៦-២០២២)

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន គឺជាគម្រោងដែលបានធ្វើការឃ្លាំមើលលំហសង្គមស៊ីវិលនៅកម្ពុជាជាច្រើនឆ្នាំមកហើយ រួមទាំងការឃ្លាំមើលនូវកម្រិតនៃការយល់ដឹង និងការអនុវត្តទៅលើសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ (សេរីភាពមូលដ្ឋាន)។ គម្រោងធ្វើការស្ទង់មតិជាសាធារណៈប្រចាំឆ្នាំ ដើម្បីវាស់អំពីការយល់ដឹងរបស់បុគ្គលម្នាក់ៗទៅលើសេរីភាពមូលដ្ឋាន និងសេរីភាពនៃការអនុវត្តសិទ្ធិទាំងនេះ។ ជារៀងរាល់ឆ្នាំ[១] ការស្ទង់មតិត្រូវបានធ្វើឡើងគ្រប់ខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលមានគោលដៅស្រង់មតិតាមក្រុមនៃអាយុ និងយេនឌ័រ។

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានធ្វើការស្ទង់មតិជាមធ្យមចំនួន ៩៧៥ នាក់ ក្នុង១ឆ្នាំ។ ខណៈដែលគម្រោងគ្រោងធ្វើ ១០០០ នាក់ ជារៀងរាល់ឆ្នាំ តែចំនួនអ្នកឆ្លើយតបមានការថយចុះក្នុងឆ្នាំ២០២០ និង ២០២១ ដោយសារតែវិបត្តិជំងឺកូវីដ-១៩។ ជាក់ស្តែង ក្នុងឆ្នាំ២០២២ គម្រោងបានស្ទង់មតិ ១៤២៤ នាក់។

## ភាគរយអ្នកឆ្លើយតបតាមអាយុ ដែលឆ្លើយថាយល់ច្បាស់លើសេរីភាពមូលដ្ឋានក្នុងឆ្នាំ២០២២៖

ទិន្នន័យខាងក្រោមបង្ហាញពីភាគរយអ្នកឆ្លើយតបដែលឆ្លើយថាយល់ច្បាស់លើសេរីភាពមូលដ្ឋាន បែងចែកតាមក្រុមនៃអាយុ ដោយភាគរយខ្ពស់បំផុត នៃអ្នកឆ្លើយតបថាយល់ច្បាស់អំពីសេរីភាពមូលដ្ឋានគឺមានអាយុចន្លោះពី ១៦ ដល់ ២៥ ឆ្នាំ។




## ការពិនិត្យមើលទៅលើការអនុវត្តសេរីភាពមូលដ្ឋាន

### មានសេរីភាពក្នុងការនិយាយនៅទីសាធារណៈ៖

ភាគរយអ្នកឆ្លើយតប ដែលឆ្លើយថា "មានសេរីភាព"[២] ក្នុងការនិយាយនៅទីសាធារណៈ កើនឡើងក្នុងឆ្នាំ២០២២ ប្រៀបធៀបទៅនឹងឆ្នាំ២០២១។




### មានសេរីភាពក្នុងការចូលរួមសកម្មភាពនយោបាយ៖

ភាគរយអ្នកឆ្លើយតប ដែលឆ្លើយថា "មានសេរីភាព"[៣] ក្នុងការចូលរួមសកម្មភាពនយោបាយ កើនឡើងក្នុងឆ្នាំ២០២២ បន្ទាប់ពីធ្លាក់ចុះក្នុងរយៈពេល៤ឆ្នាំចុងក្រោយ។




[១] ការស្ទង់មតិត្រូវបានធ្វើឡើងក្នុងខែតុលា ឆ្នាំ២០១៦ (២០១៦), ខែមីនា ឆ្នាំ២០១៨ (២០១៧), ខែមីនា ឆ្នាំ២០១៩ (២០១៨),ខែមីនា ឆ្នាំ២០២០ (២០១៩), ខែធ្នូ ឆ្នាំ២០២០ (២០២០), ខែធ្នូ ឆ្នាំ២០២១ (២០២១), ខែធ្នូ ឆ្នាំ២០២២ (២០២២)។

[២] ចំពោះអ្នកឆ្លើយតបថា "មានសេរីភាព" ក្នុងនោះរួមមានភាគរយអ្នកឆ្លើយតបដែលបានរាយការណ៍ថា"មានសេរីភាពខ្លាំងណាស់" ឬ "មានសេរីភាពខ្លះដែរ" ។

[៣] ដូចខាងលើ។

## មានសេរីភាពក្នុងការចូលរួមធ្វើកូដកម្មដោយសន្តិវិធី៖

នៅក្នុងឆ្នាំ២០២២ ៤២% នៃអ្នកឆ្លើយតបថា "មានសេរីភាព"[៤] ក្នុងការចូលរួមធ្វើកូដកម្មដោយសន្តិវិធី កើនឡើងចំនួន ១៨% ប្រៀបធៀបទៅនឹងឆ្នាំ២០២១។




## លទ្ធភាពដែលបុគ្គលអាចកំណត់អំពីដែនកំណត់សិទ្ធិរបស់ខ្លួន

លទ្ធភាពរបស់បុគ្គលម្នាក់ៗក្នុងការអនុវត្តសេរីភាពមូលដ្ឋាន គឺអាស្រ័យលើការយល់ដឹងអំពីប្រព័ន្ធច្បាប់ដែលទាក់ទងទៅនឹងសេរីភាពទាំងនេះ។ រាល់ឆ្នាំ កម្រងសំណួរត្រូវបានសួរដើម្បីកំណត់ទៅលើសកម្មភាពជាក់លាក់ថាតើស្របច្បាប់ ឬខុសច្បាប់។

**សេរីភាពខាងការបញ្ចេញមតិ៖** អ្នកឆ្លើយតប ដែលឆ្លើយត្រឹមត្រូវថា ជារឿងស្របច្បាប់ក្នុងការរិះគន់គោលនយោបាយរបស់រដ្ឋាភិបាល (៥៩%) មានចំនួនតិចជាងបើធៀបទៅឆ្នាំ២០២០ និងឆ្នាំ២០២១។ ចំពោះអ្នកឆ្លើយតប ដែលឆ្លើយត្រឹមត្រូវថា ជារឿងស្របច្បាប់ក្នុងការនិយាយរឿងនយោបាយ មានការកើនឡើងគួរឱ្យកត់សម្គាល់ (៧១%)។ ដូចគ្នាដែរ ភាគរយអ្នកដែលឆ្លើយត្រឹមត្រូវថា ជារឿងខុសច្បាប់ក្នុងការប្រមាថបុគ្គលសាធារណៈបានថយចុះពី ៩២% ក្នុងឆ្នាំ២០២១ មក ៨៩% ក្នុងឆ្នាំ២០២២។




**សេរីភាពខាងសមាគម៖** អ្នកឆ្លើយតបភាគច្រើន ដែលឆ្លើយត្រឹមត្រូវថា ជារឿងខុសច្បាប់ដែលបង្កើតអង្គការមិនមែនរដ្ឋាភិបាលដោយមិនចុះបញ្ជី។ ប៉ុន្តែ ភាគរយអ្នកឆ្លើយតប ដែលឆ្លើយត្រូវថា ជារឿងស្របច្បាប់ក្នុងការធ្វើសកម្មភាពរបស់សមាគម ដោយមិនជូនដំណឹងទៅអាជ្ញាធរបានថយចុះ ៦%។




**សេរីភាពខាងការជួបប្រជុំ៖** ភាគរយអ្នកឆ្លើយតប ដែលឆ្លើយត្រឹមត្រូវថា ជារឿងស្របច្បាប់ក្នុងការធ្វើកូដកម្មដោយមិនមានការអនុញ្ញាត កើនឡើងពី ២៦% ក្នុងឆ្នាំ២០២១ ទៅ ៣២% ក្នុងឆ្នាំ២០២២។ ទោះជាយ៉ាងណាក៏ដោយ ភាគរយអ្នកដែលឆ្លើយត្រឹមត្រូវថា ជារឿងស្របច្បាប់ក្នុងការចូលរួមតវ៉ាដោយសន្តិវិធី នៅមានកម្រិតទាប (គឺមានតែ ៤៦% ប៉ុណ្ណោះ)។




[៤] ដូចខាងលើ។

## <u>ភាពខុសគ្នារវាងយេនឌ័រ</u>

នៅក្នុងឆ្នាំ២០២១ អ្នកឆ្លើយតបជាស្ត្រី មានអារម្មណ៍ថាមានសេរីភាព "**ក្នុងការនិយាយដោយបើកចំហគ្រប់ប្រធានបទតាមរយៈប្រព័ន្ធផ្សព្វផ្សាយ**" ច្រើនជាងបុរស។ ទោះជាយ៉ាងនេះក៏ដោយ ភាគរយអ្នកឆ្លើយតបជាស្ត្រី និងបុរស គឺមានចំនួនប្រហាក់ប្រហែលគ្នា លើកលែងតែក្នុងឆ្នាំ២០១៩ ដែលចំនួនអ្នកឆ្លើយតបជាស្ត្រី និងបុរសហាក់មានគម្លាតឆ្ងាយដាច់ពីគ្នា។







ទិន្នន័យខាងក្រោមនេះបង្ហាញពីរបត់វិជ្ជមានជារួម ដែលមានគម្លាតកៀកគ្នានៃភាគរយអ្នកឆ្លើយតបជាបុរស និងស្ត្រី ឆ្លើយថាខ្លួន "មានសេរីភាពខ្លាំងណាស់" និង "មានសេរីភាពខ្លះដែរ" ក្នុងការចូលរួមសកម្មភាពនយោបាយ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ២០២២ បានបង្ហាញនូវគម្លាតយ៉ាងខ្លាំងពីឆ្នាំ២០២១ នេះជាបញ្ហាដែលបន្តកើតមាន ហើយនឹងត្រូវឃ្លាំមើលតទៅទៀត។




......... ចប់............

ខែកក្កដា ឆ្នាំ២០២៣